# អង្គរបុរី
## សម្លេងខ្មែរនៅបរទេស

# ការវិភាគ
## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ ព្រះសម្ពុទ្ធរកឃើញផ្លូវប្រតិបត្តិចេញចាកទុក្ខ
## ជាតម្លៃខ្ពស់បំផុតរបស់ព្រះពុទ្ធសាសនា

website: www.hoksavann.org
ថ្ងៃទី២៣ កក្កដា ២០០៧



ព្រះសម្ពុទ្ធបានប្រកាសនៅពេលដែលព្រះអង្គបានសំដែងធម៌ទេសនាប្រោសភិក្ខុ៥អង្គថា ផ្លូវអមខាងទាំងពីរ គឺទី១ ឈ្មោះកាមសុខល្លិកានុយោគ ចិត្តត្រេកអរនូវសេចក្តីសុខក្នុងកាមគុណទាំង៥គឺ រូប សម្លេង ក្លិន រស និងសម្ផស្ស ជាធម៌របស់អ្នកស្រុក ជាធម៌ថោកទាប ជាធម៌របស់មនុស្សបុថុជ្ជន ពុំមែនជាធម៌របស់អរិយបុគ្គល ដែលនាំឲ្យឃើញអរិយសច្ច៤ទេ មិនប្រកបដោយប្រយោជន៍ឡើយ ព្រោះការជាប់ចិត្តបែបនេះនាំឲ្យខ្សោយបញ្ញា មិនអាចត្រាស់ដឹងបានឡើយ ។ តថាគតធ្លាប់បានជួបផ្លូវនេះរួចហើយ កាលនៅក្នុងព្រះរាជវាំង ។ ផ្លូវនេះចាត់ទុកជាផ្លូវអមខាង ជាផ្លូវស្តាំបំផុត ។ ផ្លូវទី២ឈ្មោះ អត្តកិលមថានុយោគ ព្យាយាមប្រព្រឹត្តធ្វើឲ្យលំបាកកាយដោយវិធីផ្សេងៗ មានខែត្រដាក់ចុះត្រាំទឹក ខែក្តៅឈរឬអង្គុយហាលថ្ងៃ ឈរតែជើងម្ខាង ដេកលើបន្លា ដកដង្ហើមតិចៗ បន្ថយអាហារ ដើម្បីឲ្យស្ងួតកិលេសដោយយល់ខុសថា កិលេសនៅក្នុងកាយ ធម៌នេះធ្វើឲ្យលំបាកកាយ មិនមែនជាធម៌របស់អរិយបុគ្គលទេ មិនប្រកបដោយប្រយោជន៍ឡើយ ។ វិធីប្រតិបត្តិបែបនេះ ក៏តថាគតធ្លាប់បានអនុវត្តហើយ ចាត់ទុកជាផ្លូវអមខាង ជាផ្លូវឆ្វេងបំផុត ។

ព្រះសម្ពុទ្ធជាកំពូលនៃលោកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មជ្ឈិមា បដិបទា ជាផ្លូវប្រតិបត្តិកណ្តាល ព្រោះឃើញទោសក្នុងផ្លូវអមខាងទាំងពីរ ជាផ្លូវប្រតិបត្តិដើម្បីកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីដឹងច្បាស់ប្រាកដ ប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងចំពោះ ដើម្បីដឹងប្រពៃ ដើម្បីរំលត់ទុក្ខ ។ មគ្គប្រកបដោយអង្គ៨នេះឯង ហៅថាការប្រតិបត្តិថ្នាក់កណ្តាល គឺ សម្មាទិដ្ឋិ ប្រាជ្ញាយល់ឃើញត្រូវ, សម្មាសង្កប្បោ ការត្រិះរិះត្រូវ, សមាវាចា

វាចាត្រូវ, សម្មាកម្មន្តោ ការងារត្រូវ, សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ, សម្មាវាយាមោ ការព្យាយាមត្រូវ, និងសម្មាសមាធិ ការដំកល់ចិត្តត្រូវ ។ បើរួមឲ្យខ្លីមានបីគឺ សីល សមាធិ និង បញ្ញា ។ សម្មាទិដ្ឋិ និងសម្មាសង្កប្បោ ជាតួបញ្ញា ។ សម្មាវាចា សម្មាកម្មន្តោ និងសម្មាអាជីវោ ជាតួសីល ។ សម្មាវាយាមោ សម្មាសតិ និង សម្មាសមាធិ ជាតួសមាធិ ។ អដ្ឋង្គិកមគ្គនេះ លោករៀងបញ្ញានៅខាងដើម ប្លែកពីត្រៃសិក្ខា ដែលរៀងបញ្ញានៅខាងចុង គឺសីលសមាធិបញ្ញា មកពីវិធីបច្ចេកទេសរបស់ព្រះពុទ្ធ ក្នុងការសំដែងធម៌ទេសនាប្រោសភិក្ខុ៥អង្គ ។ ព្រះអង្គចាំបាច់ត្រូវតែសំដែងអំពីបញ្ញាមុន ដើម្បីឲ្យភិក្ខុទាំង៥អង្គយល់ថា ព្រះពុទ្ធត្រាស់ដឹងហើយ ឲ្យភិក្ខុទាំងនោះយកចិត្តទុកដាក់ស្តាប់ ព្រោះសីលនិងសមាធិ ភិក្ខុនោះធ្លាប់អនុវត្តមកហើយ ។ តែអ្នកសិក្សាព្រះពុទ្ធសាសនាគប្បីយល់ថា បញ្ញានេះជាបញ្ញាលោកុត្តរៈ កើតឡើងបានលុះត្រាតែមានសីលនិងសមាធិប្រកបជាមួយ ហើយពុំមែនជាបញ្ញា កើតពីការស្តាប់និងការត្រិះរិះពិចារណា ជាតួបរិយត្តិធម៌នោះទេ តែជាតួបញ្ញាកើតពីការប្រតិបត្តិ វិបស្សនា ភាវនា ទើបកើតបញ្ញាជាលោកុត្តរៈ ជាបដិវេធធម៌ ឃើញអរិយសច្ច៤ ។ ការដើរតាមមគ្គប្រកបដោយអង្គ៨ឃើញអរិយសច្ច៤គឺ សេចក្តីទុក្ខបានដល់ការកើតឡើងនៃខន្ធ៥គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ១, ហេតុដែលនាំឲ្យកើតទុក្ខ បានដល់តណ្ហា១, ការរំលត់ទុក្ខបានដល់ការឈប់មានជាតិ១, ផ្លូវទៅកាន់ការរំលត់ទុក្ខបានដល់មគ្គប្រកបដោយអង្គ៨ដូចបានពោលមកហើយ១ (ទុក្ខសច្ច, សមុទយសច្ច, និរោធសច្ច, មគ្គសច្ច) ។ ការត្រាស់ដឹងរបស់ព្រះពុទ្ធនេះ មិនត្រឹមតែមនុស្សលោកទេ ដែលមានការរំភើបសប្បាយរីករាយ ដំណឹងនេះបានដឹងយ៉ាងឆាប់រហ័ស ដល់ពពួកទេវតា ពួកព្រហ្ម បានសំដែងការកោតសរសើរចំពោះព្រះពុទ្ធឈ្នះមារ បានត្រាស់ដឹងរកឃើញការពិតនៃការរំដោះទុក្ខរបស់មនុស្សសត្វ ដែលពីមុនមកគ្មានអ្នកណារកឃើញ ហើយសង្ឃឹមថាខ្លួននឹងបានស្តាប់ធម៌ព្រះអង្គ ក៏ថ្វាយព្រះពរសព្វសាធុការតែរៀងៗខ្លួន។

មគ្គប្រកបដោយអង្គ៨នេះ ជាផ្លូវនៃសេចក្តីបរិសុទ្ធ ជាផ្លូវនៃការចេញចាកទុក្ខ បានដល់អមតមហានិព្វាន ។ សមណព្រាហ្មណ៍និងតាបសឥសីមុនសម័យពុទ្ធកាលក៏ដូចជាសម័យពុទ្ធកាល មិនបានឃើញផ្លូវនេះទេ ក្រោយពីព្រះអង្គបានសិក្សាពិសេសគ្រប់បែបយ៉ាង និងដោយបារមីធម៌ ដែលព្រះអង្គបានកសាងជួយជម្រុញផង ទើបព្រះអង្គរកផ្លូវត្រាស់ដឹងនេះឃើញ ហើយដោយព្រះអង្គប្រតិបត្តិតាមផ្លូវនេះ (មគ្គ៨) ក៏បានត្រាស់ជាព្រះពុទ្ធក្នុងលោក គឺការឃើញអរិយសច្ច៤នេះឯង ។ សាសនាដទៃស្វែងរកសេចក្តីសុខតែនៅក្នុងខន្ធ៥ មានរូបខន្ធជាដើម ក្នុងឋានមនុស្ស ឋានទេវតា និងឋានព្រហ្ម ។ ព្រះពុទ្ធសំដែងថា ភពទាំងបីនេះស្ថិតនៅក្រោមត្រៃលក្ខណធម៌គឺ អនិច្ចំ ទុក្ខំ និងអនត្តា កើតចាស់ឈឺស្លាប់ មិនរួចពីសេចក្តីទុក្ខទេ ជាវដ្ដសង្សារវិលស្លាប់វិលកើតរកទីបំផុតគ្មាន ។ ចំណែកព្រះនិព្វាន ទើបដល់ការរំលត់ទុក្ខ ពុំស្ថិតនៅក្រោមអំណាចមច្ចុរាជឡើយ ។

យើងបានឃើញរឿងក្នុងសាសនាព្រាហ្មណ៍និកាយ ព្រះវិស្ណុថា ពួកទេវតា និងពួកអសុរបានកាន់ក្បាលនាគ និងកន្ទុយនាគម្ខាងម្នាក់កូរសមុទ្រទឹកដោះ ដើម្បីរកទឹកអម្រឹតផឹកទៅមិនស្លាប់ ។ នេះជារឿងនិទានដំណាលប្រាសចាកការពិតរបស់សាសនាព្រាហ្មណ៍ ព្រោះអ្វី ព្រោះថាគ្មានទឹកណាផឹកទៅមិនស្លាប់នោះឡើយ កាលណាបើមានជាតិតែងតែបញ្ជូនទៅរកជរា ព្យាធិ និងមរណៈពុំខានឡើយ ។ ចំណែកព្រះនិព្វានទើបមិនស្លាប់ ទើបហៅថាអមតមហានិព្វាន ។ ក្នុងធម៌អារាធនាព្រហ្មថា ញ៉ាំងសត្វចូលពុទ្ធចក្រ មានបញ្ចវគ្គីជាអាទិ ឲ្យផឹកអម្រឹតជាតិ រសនិព្វានតាមធម្មតា ។ ពាក្យថា អម្រឹតជាពាក្យសំស្រ្កឹតប្រែថា មិនស្លាប់ ស្មើគ្នានឹងពាក្យបាលីថា អមតំ បានជាលោកពោលថា អមតំ និព្វានំ ប្រែថា និព្វានមិនស្លាប់ ។ ដូច្នេះបានសេចក្តីថា ផឹកអម្រឹតជាតិ គឺប្រតិបត្តិតាមមគ្គប្រកបដោយអង្គ៨ដូចបានពោលមកហើយ ទើបបានរសមួយ គឺនិព្វានជាធម៌មិនស្លាប់ លែងវិលកើតវិលស្លាប់ក្នុងសង្សារវដ្តជាបន្តទៅទៀត ។៚